**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

អគ្គនាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក

សេចក្តីប្រកាសព័ត៌មាន

## កម្ពុជា និងថៃបានសន្យាលើកកម្ពស់ភាពជាដៃគូយុទ្ធសាស្ត្រ

តបតាមការអញ្ជើញរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា **លោកជំទាវ ផែថងថាន ស៊ីណាវ៉ាត្រ** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ និង**ស្វាមី ឯកឧត្តម ភីដក សុខសុវត្ថិ** បានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី ២៣-២៤ ខែមេសា ឆ្នាំ២០២៥។ ដំណើរទស្សនកិច្ចនេះ គឺជាការបោះជំហានដ៏សំខាន់ថ្មីមួយ ក្នុងការពង្រឹងបន្ថែមទៀតនូវចំណងមិត្តភាពដ៏យូរអង្វែង និងភាពជាដៃគូយុទ្ធសាស្ត្ររវាងកម្ពុជា និងថៃ ស្របពេលដែលប្រទេសទាំងពីរកំពុងប្រារព្ធខួបអនុស្សាវរីយ៍លើកទី៧៥ នៃការបង្កើតទំនាក់ទំនងការទូត នៅឆ្នាំនេះ។

**លោកជំទាវ ផែថងថាន ស៊ីណាវ៉ាត្រ** បានអញ្ជើញដាក់កម្រងផ្កានៅវិមានឯករាជ្យ និងគោរពវិញ្ញាណក្ខន្ធវីរៈបុរស និងវីរនារីដ៏ឆ្នើមរបស់កម្ពុជា។ លោកជំទាវនាយករដ្ឋមន្ត្រី ក៏បានអញ្ជើញគោរពវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ «ព្រះបរមរតនកោដ្ឋ»** ព្រះវររាជបិតាជាតិខ្មែរ។

ក្នុងដំណើរទស្សនកិច្ចនេះ **លោកជំទាវនាយករដ្ឋមន្ត្រី និងឯកឧត្តម ភីដក សុខសុវត្ថិ** បានចូលក្រាបបង្គំគាល់**ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ **លោកជំទាវនាយករដ្ឋមន្ត្រី** បានចូលជួបសម្តែងការគួរសមដាច់ដោយឡែក ជាមួយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង**សម្តេចវង្សសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងស្មារតីមិត្តភាពជាប្រពៃណី ភាពជាអ្នកជិតខាងល្អ និងការយោគយល់ និងជឿទុកចិត្តគ្នាទៅវិញទៅមក **សម្តេចធិបតី នាយករដ្ឋមន្ត្រី និង លោកជំទាវនាយករដ្ឋមន្ត្រី** បានជួបពិភាក្សាយ៉ាងស៊ីជម្រៅអំពីទំនាក់ទំនងទ្វេភាគី ដែលគ្របដណ្តប់លើវិស័យជាច្រើនដែលផ្តល់ប្រយោជន៍រួមគ្នា។ **នាយករដ្ឋមន្ត្រីទាំងពីរ** បានបង្ហាញការពេញចិត្តចំពោះការរីកចម្រើននៃទំនាក់ទំនងទ្វេភាគី និងកិច្ចសហប្រតិបត្តិការដែលផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ព្រមទាំងបានប្តេជ្ញាចិត្តជាថ្មី ក្នុងការធ្វើឱ្យកាន់តែស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗដូចជា នយោបាយ ការពារជាតិនិងសន្តិសុខ កិច្ចការព្រំដែន ពាណិជ្ជកម្មនិងវិនិយោគ ការងារ អប់រំ វប្បធម៌ ទេសចរណ៍ ការតភ្ជាប់ បរិស្ថាន បច្ចេកវិទ្យានិងនវានុវត្តន៍ និងការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជន។

អំពីកិច្ចសហប្រតិបត្តិការផ្នែកនយោបាយ **នាយករដ្ឋមន្ត្រីទាំងពីរ** បានគូសបញ្ជាក់ពីសារសំខាន់នៃការផ្លាស់ប្តូរទស្សនកិច្ចគ្រប់កម្រិត និងទំនាក់ទំនងជាទៀងទាត់ រវាងប្រទេសទាំងពីរ ក្នុងការធ្វើឱ្យកាន់តែ

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

ស៊ីជម្រៅនូវទំនាកទំនងទ្វេភាគី និងពង្រីកកិច្ចសហប្រតិបត្តិការបន្ថែមទៀត។ ថ្នាក់ដឹកនាំទាំងពីរបានលើកទឹកចិត្តដល់ស្ថាប័នពាក់ព័ន្ធនៃប្រទេសទាំងពីរ ក្នុងការពិភាក្សាបញ្ចប់នូវផែនការសកម្មភាពរួមឱ្យបានឆាប់ ដើម្បីអនុវត្តភាពជាដៃគូយុទ្ធសាស្ត្ររវាងប្រទេសទាំងពីរ។ ថ្នាក់ដឹកនាំទាំងពីរ បានឯកភាពថា នឹងរៀបចំកិច្ចប្រជុំលើកទី១២ នៃគណៈកម្មការចម្រុះសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជានិងថៃឱ្យបានឆាប់។ ថ្នាក់ដឹកនាំទាំងពីរ ក៏បានឯកភាពរៀបចំកិច្ចប្រជុំគណៈរដ្ឋមន្ត្រីចម្រុះលើកទី៤ នៅខេត្តស្រះកែវ ប្រទេសថៃ នៅចុងឆ្នាំនេះ។

អំពីកិច្ចសហប្រតិបត្តិការលើវិស័យសន្តិសុខ នាយករដ្ឋមន្ត្រីទាំងពីរ បានកោតសរសើរដល់ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនៃប្រទេសទាំងពីរ ចំពោះការសម្របសម្រួលយ៉ាងជិតស្និទ្ធ និងការខិតខំប្រឹងប្រែងយ៉ាងមោះមុត ក្នុងការដោះស្រាយបញ្ហាឧក្រិដ្ឋកម្មឆ្លងដែន រួមមានការឆបោកតាមប្រព័ន្ធអ៊ីនធឺណិត ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស ជាដើម។ ថ្នាក់ដឹកនាំទាំងពីរបានប្តេជ្ញាចិត្តជាថ្មី ក្នុងការជំរុញកិច្ចសហប្រតិបត្តិការចំពោះបញ្ហាសំខាន់ៗទាំងនេះ ដើម្បីធានាសុវត្ថិភាព និងសុខុមាលភាពរបស់ប្រជាជនរបស់យើង។ កម្ពុជា បានថ្លែងអំណរគុណចំពោះគោលនយោបាយរបស់ប្រទេសថៃ ដែលមិនអនុញ្ញាតឱ្យជនណាម្នាក់ប្រើប្រាស់ទឹកដីថៃជាវេទិកា ដើម្បីជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្លួន ឬក៏ប្រព្រឹត្តសកម្មភាពទុច្ចរិតណាមួយប្រឆាំងនឹងកម្ពុជា ហើយព្រមទាំងបានបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា នឹងអនុវត្តគោលការណ៍នេះដូចគ្នា។

អំពីវិស័យសេដ្ឋកិច្ច នាយករដ្ឋមន្ត្រីទាំងពីរបានកត់សម្គាល់ដោយពេញចិត្តចំពោះកំណើនជាលំដាប់នៃទំហំពាណិជ្ជកម្មទ្វេភាគី ដែលបានកើនឡើងលើស ១០ ពាន់លានដុល្លារអាម៉េរិកជាលើកដំបូងកាលពីឆ្នាំកន្លងទៅ។ ផ្អែកលើសន្ទុះជាវិជ្ជមាននេះ ថ្នាក់ដឹកនាំទាំងពីរមានបំណងសម្រេចឱ្យបានគោលដៅ ១៥ ពាន់លានដុល្លារអាម៉េរិក ក្នុងពេលដ៏ខ្លីខាងមុខ។ ក្នុងន័យនេះ ថ្នាក់ដឹកនាំទាំងពីរបានលើកទឹកចិត្តឱ្យស្ថាប័នពាក់ព័ន្ធនៃប្រទេសទាំងពីរ ពិចារណារៀបចំកិច្ចប្រជុំគណៈកម្មាធិការពាណិជ្ជកម្មចម្រុះកម្ពុជា-ថៃ លើកទី៧ នៅឆ្នាំនេះ ដើម្បីលើកកម្ពស់ទំនាក់ទំនងពាណិជ្ជកម្ម។ ថ្នាក់ដឹកនាំទាំងពីរក៏បានឯកភាពជំរុញផងដែរ ឱ្យស្ថាប័នពាក់ព័ន្ធ ពន្លឿនការអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការ និងរៀបចំកិច្ចពិគ្រោះយោបល់អំពីការសម្រួលបន្ថែមទៀតស្តីពីពាណិជ្ជកម្មឆ្លងព្រំដែន និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច រួមមានតាមរយៈតំបន់សេដ្ឋកិច្ចពិសេសដែលបំពេញបន្ថែមគ្នាទៅវិញទៅមកនៅតាមខេត្តជាប់ព្រំដែន ដើម្បីជាផលប្រយោជន៍រួមរបស់ប្រទេសទាំងពីរ។ នាយករដ្ឋមន្ត្រីទាំងពីរ ក៏បានឯកភាពថា នឹងសម្ពោធស្ពានស្ទឹងបត់-បានណងអៀន កម្ពុជា-ថៃ ជាផ្លូវការ នៅខែកក្កដា ឆ្នាំ២០២៥។

អំពីកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ នាយករដ្ឋមន្ត្រីទាំងពីរបានស្វាគមន៍ចំពោះកំណើននៃចំនួនភ្ញៀវទេសចរណ៍រវាងប្រទេសទាំងពីរ និងបានលើកទឹកចិត្តឱ្យក្រសួងទេសចរណ៍នៃប្រទេសទាំងពីរបន្តធ្វើការសហការយ៉ាងជិតស្និទ្ធ ដើម្បីជំរុញយន្តការ «ព្រះរាជាណាចក្រពីរ គោលដៅតែមួយ»។ ថ្នាក់ដឹកនាំទាំងពីរបានគូសបញ្ជាក់ពីសារសំខាន់នៃការអនុវត្តឱ្យមានប្រសិទ្ធភាពនូវផែនការសកម្មភាពរួម ស្តីពីកិច្ចសហប្រតិបត្តិការទេសចរណ៍ ឆ្នាំ២០២៣-២០២៥ ក្នុងគោលបំណងទាក់ទាញភ្ញៀវទេសចរណ៍ជាច្រើនមកទស្សនាប្រទេសទាំងពីរ។ សម្តេចធិបតី នាយករដ្ឋមន្ត្រី បានសម្តែងការគាំទ្រចំពោះយន្តការ «ប្រទេសប្រាំមួយ គោលដៅតែមួយ» ដោយសង្ឃឹមថា នឹងលើកកម្ពស់ទេសចរណ៍ក្នុងតំបន់ និងពង្រឹងតំបន់អាស៊ីអាគ្នេយ៍ ជាគោលដៅទេសចរណ៍អន្តរជាតិដ៏លេចធ្លោ។ ក្នុងឆ្នាំ២០២៤ ទេសចរថៃឈរលេខរៀងទី១ ក្នុងចំណោមទេសចរអន្តរជាតិ ដែលមកទស្សនាកម្ពុជា ដោយមានចំនួនជាង ២លាននាក់។

អំពីវិស័យការងារ សម្តេចធិបតីនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណរាជរដ្ឋាភិបាលថៃ និងវិស័យឯកជន ដែលបានផ្តល់ឱកាសការងារ ទីកន្លែងស្នាក់នៅ និងលក្ខខណ្ឌការងារប្រកបដោយសុវត្ថិភាព ដល់ពលករកម្ពុជានៅប្រទេសថៃ។ សម្តេចធិបតីនាយករដ្ឋមន្ត្រី បានវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងបន្តបន្ទាប់របស់ប្រទេសថៃ ក្នុងការការពារសិទ្ធិ និងសុខមាលភាពរបស់ពលករកម្ពុជា ដែលមិនត្រឹមតែបានចូលរួមចំណែកដល់សេដ្ឋកិច្ចប្រទេសថៃប៉ុណ្ណោះទេ តែក៏បានទទួលនូវជំនាញ ចំណេះដឹង និងបទពិសោធដ៏មានតម្លៃ នាំត្រឡប់មកប្រទេសកម្ពុជាវិញផងដែរ។

អំពីកិច្ចសហប្រតិបត្តិការលើវិស័យវប្បធម៌ សម្តេចធិបតីនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះរដ្ឋាភិបាលថៃ ដែលសម្រេចប្រគល់នូវវត្ថុបុរាណខ្មែរចំនួន ២០ដុំ ដែលបានរឹបអូសពីក្រុមជនទុច្ចរិត នៅឆ្នាំ១៩៩៩ ត្រឡប់មកកម្ពុជាវិញ។

នាយករដ្ឋមន្ត្រីទាំងពីរ បានអបអរសាទរចំពោះការបង្កើតស្ថានអគ្គកុងស៊ុលកម្ពុជានៅខេត្តសុងខ្លា និងស្ថានអគ្គកុងស៊ុលថៃនៅខេត្តសៀមរាប ដែលនឹងសម្រួលបន្ថែមទៀតនូវទំនាក់ទំនងទ្វេភាគី ដោយផ្តល់សេវាកម្មផ្នែកកុងស៊ុលជូនប្រជាពលរដ្ឋនៃប្រទេសទាំងពីរ។

នាយករដ្ឋមន្ត្រីទាំងពីរ ក៏បានពិភាក្សាគ្នាលើវិស័យសំខាន់ៗមួយចំនួនទៀត រួមមានវិស័យធនាគារ អប់រំ កសិកម្ម បរិស្ថាន ការដឹកជញ្ជូននិងការតភ្ជាប់ ព្រមទាំងបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍។

ក្រៅពីកិច្ចសហប្រតិបត្តិការទ្វេភាគី នាយករដ្ឋមន្ត្រីទាំងពីរ បានផ្លាស់ប្តូរទស្សនៈលើបញ្ហាតំបន់ និងអន្តរជាតិ ដែលមានផលប្រយោជន៍រួម។ ថ្នាក់ដឹកនាំទាំងពីរបានអះអាងសាជាថ្មីនូវការប្តេជ្ញាចិត្តរួមក្នុងការរួមចំណែក ដើម្បីរក្សាសន្តិភាព សន្តិសុខ និងស្ថិរភាពតំបន់ និងពិភពលោក ព្រមទាំងបន្តផ្តល់ការគាំទ្រគ្នាទៅវិញទៅមកក្នុងវេទិកាអន្តរជាតិ។ ថ្នាក់ដឹកនាំទាំងពីរបានគូសបញ្ជាក់ពីសារសំខាន់នៃមជ្ឈភាព និងសាមគ្គីភាពអាស៊ាន ព្រមទាំងបង្ហាញពីការប្តេជ្ញាចិត្ត ក្នុងការជំរុញការខិតខំប្រឹងប្រែងកសាងសហគមន៍អាស៊ានរួមគ្នា ជាមួយនឹងការធ្វើឱ្យស៊ីជម្រៅនូវទំនាក់ទំនងជាមួយដៃគូខាងក្រៅ។

ខណៈប្រទេសថៃនឹងធ្វើជាម្ចាស់ផ្ទះរៀបចំកីឡាស៊ីហ្គេមលើកទី៣៣ ក្នុងខែធ្នូខាងមុខនេះ និងកីឡាប៉ារ៉ាហ្គេម នៅឆ្នាំក្រោយ សម្តេចធិបតី នាយករដ្ឋមន្ត្រី បានជូនពរឱ្យការរៀបចំព្រឹត្តិការណ៍តំបន់សំខាន់ៗទាំងនេះប្រកបដោយជោគជ័យ។ សម្តេចធិបតី ក៏បានបញ្ជាក់សាជាថ្មី នូវការគាំទ្រយ៉ាងពេញទំហឹងរបស់កម្ពុជាចំពោះប្រទេសថៃក្នុងនាមជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍នេះ។

លោកជំទាវនាយករដ្ឋមន្ត្រី ផែថងថាន ស៊ីណាវ៉ាត្រ និងឯកឧត្តម ភីដក សុខសុវត្ថិ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនដល់សម្តេចធិបតីនាយករដ្ឋមន្ត្រី និងលោកជំទាវទី១ ព្រមទាំងក្រុមការងារ ចំពោះការរៀបចំដ៏ល្អប្រសើរ និងការទទួលស្វាគមន៍ដ៏កក់ក្តៅជូនដល់គណៈប្រតិភូថៃក្នុងអំឡុងទស្សនកិច្ចផ្លូវការនេះ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៥

ឧបសម្ព័ន្ធ

ក្រោយបញ្ចប់ជំនួបទ្វេភាគី នាយករដ្ឋមន្ត្រីទាំងពីរ បានធ្វើជាសាក្សី និងស្វាគមន៍ចំពោះការចុះហត្ថលេខាលើឯកសារទ្វេភាគីដូចខាងក្រោម៖

១. អនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងធនធានធម្មជាតិ និងបរិស្ថាន នៃព្រះរាជាណាចក្រថៃ ស្តីពី «កិច្ចសហប្រតិបត្តិការកិច្ចគាំពារបរិស្ថានឆ្លងដែន»។

២. អនុស្សរណៈនៃការយោគយល់គ្នា រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពី «កិច្ចសហប្រតិបត្តិការលើវិស័យការងារ»។

៣. កិច្ចព្រមព្រៀង ស្តីពី «ការប្រើប្រាស់កម្លាំងពលកម្ម រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ»។

៤. កិច្ចព្រមព្រៀង រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពី «ការគ្រប់គ្រង ថែទាំ និងប្រើប្រាស់ស្ពានមិត្តភាពកម្ពុជា-ថៃ (ស្ទឹងបត់-បានណាងអៀន)»។

៥. កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពី «ការសាងសង់ស្ពានព្រំដែនផ្សារព្រំ-បានផាកាត»។

៦. កំណត់ហេតុរវាងក្រសួងសាធារណការ និងដឹកជញ្ជូននៃព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការដើម្បីអភិវឌ្ឍសេដ្ឋកិច្ចនៃប្រទេសជិតខាងនៃព្រះរាជាណាចក្រថៃ ស្តីពីការផ្តល់ជំនួយបច្ចេកទេសលើការសិក្សាសមិទ្ធិលទ្ធភាពលើគម្រោងធ្វើឱ្យប្រសើរឡើងកំណាត់ផ្លូវជាតិលេខ ៥៧ (បាត់ដំបង-ប្រកទ្វារអន្តរជាតិព្រំ)

៧. លិខិតប្តូរសារ ស្តីពី «គម្រោងពង្រឹងសមត្ថភាពនៃវិទ្យាស្ថានអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ»។